ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤២៣
ចុះថ្ងៃទី ០៦-៥-២០១៣
សាលដីកា
លេខ: ១៦ "ក្រVបស"
ថ្ងៃទី ២៦-០២-២០១៤

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ១៧-០២-២០១៤ ដែលមានសមាសភាពដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៤២៣ ចុះថ្ងៃទី ០៦-០៥-២០១៣ របស់សាលាឧទ្ធរណ៍ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ស៊ីក ហៅ ស្លេះ ស៊ីកគ្រីយ៉ា ហៅ វ៉ាន់ ស៊ីកគ្រីយ៉ា ភេទប្រុស អាយុ ៦៧ ឆ្នាំ ជាតិខ្មែរឥស្លាម មានទីកន្លែងកំណើតនៅភូមិគៀនរមៀត ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ [redacted] មុខរបរកសិករ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន ០៥ នាក់ ទោសពីមុនគ្មាន ជានីតិជន។

-ឃាត់ខ្លួននៅថ្ងៃទី ២២-៧-២០១២ និងឃុំខ្លួនតាមដីកាបង្គាប់អោយឃុំខ្លួនលេខ: ១៤០១ តព្រ នៅថ្ងៃទី ១៤-៨-២០១២ ។

២-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរកម្មករ មានទីកន្លែងកំណើតនៅភូមិទួលពន្លៃ ឃុំជីរោទ៍ ស្រុកសួង ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅគីឡូម៉ែត្រលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ជានីតិជន។

២៨៤

(ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

Scanned with CamScanner

-ឃោរឃុំខ្លួននៅថ្ងៃទី ២២-៧-២០១២ និងឃុំខ្លួនតាមដីកាបង្គាប់អោយឃុំខ្លួនលេខៈ ១៤០២ តព្រ នៅថ្ងៃទី ១៤-៧-២០១២ ។

៣-ជនជាប់ចោទឈ្មោះ [redacted] រ៉ស៊ីត ហៅប្រុស ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរឥស្លាម មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ។

-ដីកាបង្គាប់អោយចាប់ខ្លួនលេខ ៤៥០ តព្រ ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១២ ។

៤-ជនជាប់ចោទឈ្មោះ [redacted] សិបព្រី ហៅព្រី ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរឥស្លាម សាសនាឥស្លាម មានទីកន្លែងកំណើតនៅភូមិឆ្នោត ឃុំគគីរ ស្រុកមេមត់ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ប្តីឈ្មោះ [redacted] មានកូន ០៣នាក់ ជានីតិជន ។

-ដីកាបង្គាប់អោយចាប់ខ្លួនលេខ ៤៤៩ តព្រ ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១២ ។

៥-ជនជាប់ចោទឈ្មោះ [redacted] សាលិកា ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរឥស្លាម សាសនាឥស្លាម មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ។

-ដីកាបង្គាប់អោយចាប់ខ្លួនលេខ ៤៨០ តព្រ ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១២ ។

-ជាប់ចោទពីបទៈ ឆបោក ប្រព្រឹត្តនៅចំណុច១១ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៨០ ត្រង់ចំនុច៥ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ មាន ៖

១-ឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិអណ្តូងកញ្ជរ ឃុំរូង ស្រុកមេមត់ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] ជានីតិជន ។

២-ឈ្មោះ [redacted] រ៉ោះ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិត្រពាំងខ្ចិង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] ជានីតិជន ។

៣-ឈ្មោះ [redacted] មូហ៊ីម ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិចំរើន ឃុំវាលម្លូ ស្រុកបញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។

៤-ឈ្មោះ [redacted] ហុន ភេទស្រី អាយុ ៦៥ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរកសិករ មានទីកន្លែងកំណើតភូមិរំសែង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] ជានីតិជន (តំណាងឲ្យកូនឈ្មោះ [redacted]) ។

២៨៥



Scanned with CamScanner

៥-ឈ្មោះ [redacted] វាន់នី ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិពោធិ៍ឥន្ទ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅ [redacted] ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។

៦-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] មូសា ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ មានទីកន្លែងកំណើតភូមិអណ្តូងខ្លួរ ឃុំរូង ស្រុកមេមត់ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។

៧-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ម៉ាអេល ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរចំការ មានទីកន្លែងកំណើតភូមិព្រះដៅ ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។

៨-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ម៉ាត់ ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើចំការ មានទីកន្លែងកំណើតភូមិឡ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។

៩-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] រ៉ូម៉ាស ភេទប្រុស អាយុ ៧៤ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរធ្វើចំការ មានទីកន្លែងកំណើតនៅភូមិព្រះដៅ ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។

១០-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ធន ភេទប្រុស អាយុ ៦០ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរ ធ្វើចំការ មានទីកន្លែងកំណើតនៅភូមិឆ្វេង ឃុំស្រែទុំ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ជានីតិជន (បង់លុយឲ្យស្លេះ សឹក ចំនួន ២០ម៉ឺនរៀល) ។

១១-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ជេត ភេទស្រី អាយុ ៣៣ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរធ្វើចំការ មានទីកន្លែងកំណើតនៅភូមិឡ ឃុំក្រញូង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ន [redacted] ជានីតិជន (បង់លុយឲ្យស្លេះ សឹក ចំនួន ២០ម៉ឺនរៀល) ។

១២-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] អៀត ភេទស្រី អាយុ ៦០ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរធ្វើចំការ មានទីកន្លែងកំណើតនៅភូមិអណ្តូងជ័រ ឃុំរូង ស្រុកមេមត់ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅ [redacted] ជានីតិជន (បង់លុយឱ្យ [redacted] សឹក ចំនួន ២០ម៉ឺនរៀល)

១៣-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ស្លេះ ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរ ធ្វើចំការ មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម



Scanned with CamScanner

បានទីលំនៅបច្ចុប្បន្ននៅភូមិផ្លែង [redacted] ជានីតិជន (បង់លុយឲ្យ [redacted] ស៊ីកចំនួន ៦០ម៉ឺនរៀល)។

១៤-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ហាំម៉ាត់ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ-ឥស្លាម មុខរបរធ្វើចំការ មានទីកន្លែងកំណើតនៅភូមិឆ្លូងទី១ ឃុំកំពាន់ ស្រុកមេមត់ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅ [redacted] ជានីតិជន (បង់លុយឲ្យ [redacted] ស៊ីក ចំនួន ២០ម៉ឺនរៀល)

១៥-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] អូម៉ាន ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរ ធ្វើចំការ មានទីកន្លែងកំណើតនៅភូមិឆ្លូងទី១ ឃុំកំពាន់ ស្រុកមេមត់ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅ [redacted] ជានីតិជន (បង់លុយឲ្យ [redacted] ស៊ីក ចំនួន ២០ ម៉ឺនរៀល)។

## ឯរឿងហេតុមានដូចតទៅ៖

សកម្មភាព ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីអំឡុងខែកក្កដា ឆ្នាំ២០១១ មានឈ្មោះ [redacted] ស៊ីក ហៅ វ៉ាន់ ស៊ីកគ្រីយ៉ា ភេទប្រុស អាយុ ៥៨ឆ្នាំ បានដើរប្រមូលប្រាក់ពីប្រជាពលរដ្ឋ ដោយក្នុងមួយគ្រួសារ យកចាប់ពី ២០០,០០០រៀល (ម្ភៃលានរៀល) រហូតដល់ ៦,០០០,០០០រៀល (ប្រាំមួយលានរៀល) ថាយកទៅឲ្យឈ្មោះ [redacted] សាលិកា ភេទស្រី អាយុ ៣៥ឆ្នាំ,ឈ្មោះ [redacted] វ៉ាន់ ភេទប្រុស អាយុ៤៤ឆ្នាំ, ឈ្មោះ [redacted] សិបព្រី ភេទស្រី អាយុ ៤៤ឆ្នាំ និងឈ្មោះ [redacted] រ៉ាសីន ភេទប្រុស អាយុ ៣០ឆ្នាំ ដើម្បីយកទៅរត់ការទៅថ្នាក់លើស្នើសុំដីនៅចំនុចគីឡូម៉ែត្រលេខ ១០១ ដល់ចំនុច គីឡូម៉ែត្រ ១១១ ស្ថិតនៅក្នុងឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដោយអ្នកទាំងប្រាំនាក់ខាងលើនេះបានសន្យាជាមួយប្រជាពលរដ្ឋ ថានឹងចែកដីឲ្យនៅចំនុចខាងលើ ចាប់ពីក្បាលដីទំហំ ៥០ម៉ែត្រ និងជម្រៅ ១០០០ ម៉ែត្រ ឡើងទៅ នៅពេលនោះឈ្មោះ [redacted] ស៊ីក បានដើរប្រមូលប្រាក់បានពីប្រជាពលរដ្ឋ បានប្រហែលជាង ៤០០គ្រួសារ ហើយស្រាប់តែមកដល់ថ្ងៃមកយកដី ឈ្មោះ [redacted] ស៊ីក,ឈ្មោះ [redacted] សាលិកា,ឈ្មោះ [redacted] វ៉ាន់,ឈ្មោះ [redacted] សិបព្រី និងឈ្មោះ [redacted] រ៉ាសីន ពុំមានដីឲ្យប្រជាពលរដ្ឋទាំងអស់នោះ ក៏បានដាក់ពាក្យបណ្តឹងមកអយ្យការ អមសាលាដំបូងខេត្តក្រចេះ ដើម្បីជួយចាត់ការទៅលើឈ្មោះទាំងបួនខាងលើ លុះមកដល់ថ្ងៃទី ១៤.០៦.២០១២ អយ្យការអម សាលាដំបូងខេត្តក្រចេះ បានផ្ទេរសមត្ថកិច្ចមកអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

**បានឃើញ** សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ: ២០ "ខ" ចុះថ្ងៃទី ២៧-០៣-២០១៣ ថា៖

១-ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក-ឈ្មោះ [redacted] ស៊ីក ហៅ ស្លេះ ស៊ីកគ្រីយ៉ា ហៅ វ៉ាន់ ស៊ីកគ្រីយ៉ា ភេទប្រុស អាយុ ៦៧ឆ្នាំ

ខ-ឈ្មោះ [redacted] វ៉ាន់ ភេទប្រុស អាយុ ៤៧ឆ្នាំ

គ-ឈ្មោះ [redacted] រ៉ាស៊ីត ហៅប្រុស ភេទប្រុស អាយុ ៣៣ឆ្នាំ

ឃ-ឈ្មោះ [redacted] សិបព្រី ហៅព្រី ភេទស្រី អាយុ ៤៤ឆ្នាំ

ង-ឈ្មោះ [redacted] សាលិកា ភេទស្រី អាយុ ៣៥ឆ្នាំ



Scanned with CamScanner

ដាក់ពន្ធនាគារម្នាក់ៗ កំណត់រយៈពេល ០២ឆ្នាំ ០៦ខែ (ពីរឆ្នាំ ប្រាំមួយខែ) ។

ពីបទៈ ឆបោក ប្រព្រឹត្តនៅចំណុច១១១ ឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៨០ ត្រង់ចំនុច៥ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ុក ហៅ ស្លេះ ស៊ុកគ្រយ៉ា ហៅ វ៉ាន់ ស៊ុកគ្រយ៉ា, ឈ្មោះ [redacted] វ៉ាន់, ឈ្មោះ [redacted] វ៉ុស៊ើត, ឈ្មោះ [redacted] សិបព្រី ហៅព្រី និងឈ្មោះ [redacted] សាលិកា រួមគ្នាសងសំណង ទៅដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោមៈ

ក.ឈ្មោះ [redacted] ម៉ារី ចំនួន ៤០ម៉ឺនរៀល (សែសិបម៉ឺនរៀល)

ខ.ឈ្មោះ [redacted] ប៉ោះ ចំនួន ២០ម៉ឺនរៀល (ម្ភៃម៉ឺនរៀល)

គ.ឈ្មោះ [redacted] មូហ៊ីម ចំនួន ៦០ម៉ឺនរៀល (ហុកសិបម៉ឺនរៀល)

ឃ.ឈ្មោះ [redacted] ហុន ចំនួន ៥០ម៉ឺនរៀល (ហាសិបម៉ឺនរៀល)

ង.ឈ្មោះ [redacted] វ៉ាន់នី ចំនួន ១លាន ៤០ម៉ឺនរៀល (មួយលាន សែសិបម៉ឺនរៀល) ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] ស៊ុក, ឈ្មោះ [redacted] វ៉ាន់, មេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ារី, ឈ្មោះ [redacted] ប៉ោះ, ឈ្មោះ [redacted] វ៉ាន់នី, ឈ្មោះ [redacted] មូសា, ឈ្មោះ [redacted] ម៉ាអេល, ឈ្មោះ [redacted] ម៉ាត់, ឈ្មោះ [redacted] សាលិកា, ឈ្មោះ [redacted] ស្លេះ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វ៉ុស៊ើត, ឈ្មោះ [redacted] ម៉ាត់, ឈ្មោះ [redacted] រ៉ូម៉ាស, ឈ្មោះ [redacted] ស្លេះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មូហ៊ីម, ឈ្មោះ [redacted] ហុន, ឈ្មោះ [redacted] ឆន, ឈ្មោះ [redacted] ជេត, ឈ្មោះ [redacted] អៀត, ឈ្មោះ [redacted] ហាំម៉ាត់, ឈ្មោះ [redacted] អូម៉ាន និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៣ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ៣០៤,៣០៥ ចុះថ្ងៃទី ២៥-០៤-២០១៣ របស់ឈ្មោះ [redacted] ស៊ុក និងឈ្មោះ [redacted] វ៉ាន់ ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ២០ "ខ" ចុះថ្ងៃទី ២៧-០៣-២០១៣ ត្រង់ចំនុចនៃសេចក្តីសម្រេចសាលក្រមទាំងមូល ។

**បានឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌលេខៈ ៤២៣ ចុះថ្ងៃទី ០៦-០៥-២០១៣ របស់ចៅក្រម នៃសាលាឧទ្ធរណ៍ ។

**បានឃើញ** សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ុក (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ (វត្តមាន)

-មេធាវីការពារជនជាប់ចោទលោក [redacted] សុផល, [redacted] តុលា (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ

១-ឈ្មោះ [redacted] ម៉ារី (អវត្តមាន)

២-ឈ្មោះ [redacted] ប៉ោះ (អវត្តមាន)

(អវត្តមាន)

Scanned with CamScanner

៤-ឈ្មោះ [redacted] ហុន (អវត្តមាន)
៥-ឈ្មោះ [redacted]ាន់នី (អវត្តមាន)
៦-ឈ្មោះ [redacted] មូសា (អវត្តមាន)
៧-ឈ្មោះ [redacted] ម៉ាអេល (អវត្តមាន)
៨-ឈ្មោះ [redacted] ម៉ាត់ (អវត្តមាន)
៩-ឈ្មោះ [redacted]រ៉ូម៉ាស (អវត្តមាន)
១០-ឈ្មោះ [redacted] ធន (អវត្តមាន)
១១- ឈ្មោះ [redacted] ជេត (អវត្តមាន)
១២-ឈ្មោះ [redacted] អៀត (អវត្តមាន)
១៣-ឈ្មោះ [redacted]ស្លេះ (អវត្តមាន)
១៤-ឈ្មោះ [redacted] ហាំម៉ាត់ (អវត្តមាន)
១៥-ឈ្មោះ [redacted] អូម៉ាន (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីក បានឆ្លើយថា: ខ្ញុំបានទទួលលុយ ៣ លានរៀល ចំពោះ ១៥ នាក់ តែអ្នកទាំងនោះមិនបានប្ដឹងមកទារលុយទេ ខ្ញុំមិនបានប្រព្រឹត្តទេ តុលាការផ្ដន្ទាទោសខ្ញុំ២ឆ្នាំ៦ខែ អ្នកទាំងនោះមកអង្វរខ្ញុំបានរៃលុយ ១ គ្រួសារ ២០ ម៉ឺនរៀល ទាំងអស់ ១៥ គ្រួសារ ខ្ញុំបានយកលុយនោះមកភ្នំពេញ ៥ នាក់ឈ្មោះ [redacted] រ៉ស៊ើត [redacted] សិបត្រី, [redacted] សាលីកា លុយនោះគ្រាន់តែជាលុយហ៊ុយមកភ្នំពេញទេ ខ្ញុំសុំសងលុយ៣លានរៀលវិញ។ ឈ្មោះ [redacted]សាលីកា ជាអ្នកផ្ដើមគំនិត គាត់ទៅបាំងហើយ។ លុយយកពីប្រជាពលរដ្ឋនោះ [redacted] វ៉ាន់ មិនបានយកចាយទេ លុយ ៣.០០០.០០០ លាន នោះខ្ញុំទទួលសងម្នាក់ឯង ក្នុងចំណោម៤០០គ្រួសារ ១៥ គ្រួសារ បានផ្ដល់លុយ ២០ ម៉ឺនក្នុង ១ គ្រួសារ ហើយ ១៥គ្រួសារ នោះមិនទាមទារទេ។ សូមតុលាការផ្ដល់យុត្តិធម៌។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ បានឆ្លើយថា: ខ្ញុំគ្រាន់តែជាតំណាងស្នើសុំដីរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋ ១៥ គ្រួសារមិនមានដីនៅទីនោះទេ។ ខ្ញុំមិនបានចាយលុយរៃនោះទេសុំរួចបទចោទ។

<u>**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**</u>

បទល្មើសតូចតាចទេ សុំព្យួរទោស ឬអាចឱ្យនៅក្រៅឃុំបាន។

<u>**សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ**</u>

-មេធាវីលោក [redacted] តុលា បានធ្វើសេចក្ដីសន្និដ្ឋានថា: ការចោទប្រកាន់មិនត្រឹមត្រូវទេ គឺប្រជាពលរដ្ឋបានមកពឹងពាក់គាត់ឱ្យមកជួយសុំដីជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋបានបង់លុយ២០ម៉ឺនរៀលជាការជួយជាសោហ៊ុយ ដើម្បីមកភ្នំពេញសុំចំណារសុំលិខិតការអនុញ្ញាតិផ្ដល់ដី មិនទាក់ទងបទល្មើសឆបោកទេ។

-មេធាវីលោក [redacted] សុផល បានធ្វើសេចក្ដីសន្និដ្ឋានថា: អំពើរបស់កូនក្ដីខ្ញុំមិនមានធាតុផ្សំបទល្មើសឆបោកនោះទេ ពួកគាត់ ១៥ គ្រួសារ បានសម្រេចចិត្តចេញសោហ៊ុយឱ្យគាត់មកសុំចំណារសុំលិខិតអន្តរាគមន៍ដើម្បីបានដីរស់នៅ។ សុំឱ្យកូនក្ដីរួចបទចោទ ហើយមានតំណាងសងប្រាក់ទៅតំណាង ១៥គ្រួសាររួចហើយ ហេតុនេះសូមលើកលែងចោទលើកូនក្ដីរបស់ខ្ញុំ។

២៨៩



Scanned with CamScanner

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី
-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់។

## សាលាឧទ្ធរណ៍
## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ៣០៤ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ស៊ីក និងបណ្តឹងឧទ្ធរណ៍លេខៈ ៣០៥ ចុះថ្ងៃទី ២៥-៤-២០១៣ របស់ឈ្មោះ [redacted] វ៉ាន់ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] ស៊ីក បានឆ្លើយថាៈ ខ្លួនបានទទួលប្រាក់ពីប្រជាពលរដ្ឋចំនួន ១៥ គ្រួសារ សរុប ៣ លានរៀល ដោយសារអ្នកទាំងនោះមកពឹងពាក់ខ្លួន ដែលជាអ្នកចាស់ទុំក្នុងស្រុកឱ្យជួយឡើងមកភ្នំពេញ ដើម្បីជួបថ្នាក់ដឹកនាំសុំដីដែលពួកគាត់បានកាន់កាប់។ ប្រាក់ទាំងនោះប្រជាពលរដ្ឋប្រមូលគ្នាឱ្យ ដើម្បីជាសោហ៊ុយមកភ្នំពេញ អ្នកចូលរួមជាមួយខ្លួនពេលនោះមានឈ្មោះ [redacted] វ៉ាន់, ឈ្មោះ [redacted] រ៉ស៊ើត,ឈ្មោះ [redacted] ឋិបស្រី និងឈ្មោះ [redacted] សាលិកា ។ ឈ្មោះ [redacted] វ៉ាន់ មកភ្នំពេញជាមួយពួកខ្លួនដែរ តែមិនបានដឹងលឺរឿងប្រាក់ទេ។ ខ្លួនសុំសងប្រាក់ទាំងនោះទៅប្រជាពលរដ្ឋវិញ សុំតុលាការបន្ធូរបន្ថយទោសផង។

៣-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ បានឆ្លើយថាៈ ខ្លួនបានទទួលការពឹងពាក់ពីប្រជាពលរដ្ឋចំនួន ៤០០ គ្រួសារ ដើម្បីធ្វើពាក្យស្នើសុំដីពីថ្នាក់ដឹកនាំនៅភ្នំពេញ។ ខ្លួនមិនបានទទួលប្រាក់ពីប្រជាជនចំនួន ១៥ គ្រួសារទេ។ ពេលមកភ្នំពេញ បានឡើងមកទាំង ៥ នាក់ តែខ្លួនជិះរថយន្តផ្សេង ហើយឈ្មោះ ស្លេះ ស៊ីក ជាអ្នកចេញថ្លៃហូបបាយ។

៤-តំណាងមហាអយ្យការបានសន្និដ្ឋានថាៈ អំពើរបស់ជនជាប់ចោទជាជនល្មើសតូចតាចជនជាប់ចោទសុខចិត្តចេញសងប្រជាពលរដ្ឋវិញ ដូច្នេះគួរតុលាការពិចារណាពីទណ្ឌកម្មឡើងវិញ ដោយសម្រេចព្យួរទោស។

៥-មេធាវីការពារឱ្យជនជាប់ចោទ បានសន្និដ្ឋានថាៈ ការចោទប្រកាន់របស់តុលាការមិនត្រឹមត្រូវទេ ព្រោះប្រជាជនជាអ្នកមកពឹកពាក់ឱ្យជនជាប់ចោទជួយ ហើយជនជាប់ចោទក៏បានជួយចាត់ការលើឯកសារនោះ រហូតបានចំណាយមួយចំនួនផងដែរ។ សុំរួចផុតបទចោទប្រកាន់។

៦-តាមចម្លើយដើមបណ្តឹងបានបញ្ជាក់នៅសាលាដំបូង ថាពួកខ្លួនបានប្រគល់ប្រាក់ឱ្យជនជាប់ចោទ ដើម្បីយកទៅរត់ការសុំដីពីថ្នាក់លើ ហើយជនជាប់ចោទបានអះអាងថា បើសុំមិនបានគាត់ប្រគល់ប្រាក់វិញ ប៉ុន្តែពេលរត់ការមិនបានដី ប្រាក់ក៏មិនប្រគល់ឱ្យវិញដែរ។

៧-អំពើរបស់ជនជាប់ចោទ បាននិយាយឱ្យដើមបណ្តឹងជឿទុកចិត្ត ហើយប្រគល់ប្រាក់ឱ្យ ដើម្បីជាការដោះដូរជាមួយការស្នើសុំ ឱ្យរដ្ឋអំណាចប្រគល់ដីតាមរយៈអ្នករត់ការ ជនជាប់ចោទទាំង ៥ នាក់។ ប៉ុន្តែជនជាប់ចោទមិនបានចាត់ការតាមសំណូមពររបស់ប្រជាពលរដ្ឋទេ បែរជាយកប្រាក់របស់អ្នកទាំងនោះទៅចាយ ហើយមិនប្រគល់ឱ្យវិញ គឺជាអំពើល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ តាមមាត្រា ៣៧៧ និងមាត្រា ៣៨០។ ប៉ុន្តែដោយជនជាប់ចោទសុខចិត្តទទួលខុសត្រូវនូវសំណង និងទទួលកំហុសរបស់ខ្លួន គប្បីតុលាការពិចារណា ដល់ការព្យួរទោសមួយផ្នែក។



Scanned with CamScanner

៨-តុលាការសាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុបញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ។

-សេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខៈ ២០ "ខ" ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល លើកលែងតែទណ្ឌកម្មលើ ជនជាប់ចោទឈ្មោះ [redacted] ស៊ីក ហៅ ស្លេះ ស៊ីកគ្រីយ៉ាង ហៅ វ៉ាន ស៊ីកគ្រីយ៉ា និងឈ្មោះ [redacted]វ៉ាន់ គប្បីតុលាការពិចារណា មាត្រា ១០៧,១០៨ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ៣០៤ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ស៊ីក និងបណ្តឹងឧទ្ធរណ៍លេខៈ ៣០៥ ចុះថ្ងៃទី ២៥-៤-២០១៣ របស់ឈ្មោះ [redacted]វ៉ាន់ ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ២០ "ខ" ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ស៊ីក ហៅ [redacted] ស៊ីកគ្រយ៉ា និងជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ ត្រូវកែប្រែពីទោសអនុវត្តពន្ធនាគារ ២ ឆ្នាំ ៦ខែ កែមកអនុវត្តទោសពន្ធនាគារចំនួន ១ ឆ្នាំ ៧ ខែ ទោសនៅសល់ ១១ ខែ ត្រូវព្យួរ (ទោសព្យួរធម្មតា)។

-ចំណុចផ្សេងពីនេះរក្សាទុកដដែល។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៧-០២-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីក, ឈ្មោះ [redacted]វ៉ាន់ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៦-០២-២០១៤ ។

-បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកានេះ ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី២៥ ខែ..០៣......ឆ្នាំ២០១៤

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]

២៩១